# វគ្គបណ្តុះបណ្តាលស្តីពី
# បទអន្តរាគមន៍បង្ការមេរោគអេដស៍លើក្រុមប្រឈមមុខខ្ពស់ តាមបែបនិម្មិត
# Training on HIV Virtual Intervention for Key Population
# ថ្ងៃពុធ ១កើត ដល់ថ្ងៃព្រហស្បតិ៍ ខែ ចេត្រ ឆ្នាំ ខាល ចត្វាស័ក ព.ស ២៥៦៦
# ភូមិគ្រឹះនាងគង្ហីង ខេត្តកំពង់ចាម

**កាលបរិច្ឆេទ និងទីកន្លែង**

វគ្គបណ្តុះបណ្តាលស្តីពី បទអន្តរាគមន៍បង្ការមេរោគអេដស៍លើក្រុមប្រឈមមុខខ្ពស់ តាមបែបនិម្មិត ដល់មន្ត្រីអប់រំផ្ទាល់តាមបែបនិម្មិត មកពីអង្គការ រ៉ាក់ (ខេត្តកំពង់ធំ បន្ទាយមានជ័យ) អង្គការ CWPD (ភ្នំពេញ កណ្តាល ព្រៃវែង ព្រះសីហនុ) អង្គការ MHC (ភ្នំពេញ កណ្តាល ព្រៃវែង ព្រះសីហនុ ត្បូងឃ្មុំ កំពង់ស្ពឺ តាកែវ) អង្គការ MHCC (ភ្នំពេញ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន) អង្គការ FHI 360 (EpiC) និងមន្ត្រីមកពីមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដែលមានសិក្ខាកាមចូលរួមចំនួន ៤៥ រូប បានប្រព្រឹត្តទៅនៅ ភូមិគ្រឹះនាងគង្ហីង ខេត្តកំពង់ចាម ថ្ងៃទី ២២ ខែ មីនា ដល់ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២៣ ដែលរៀបចំឡើង ដោយផ្នែកប្រាស្រ័យទាក់ទងដើម្បីផ្លាស់ប្តូរការប្រព្រឹត្ត និងផ្នែកគ្រប់គ្រងទិន្នន័យ នៃមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ ដោយទទួលបាននូវការឧបត្ថមថវិកាពី DFAT/UNAIDS, ។

**គោលបំណង៖**

- ដើម្បីទាក់ទង ក្រុមគោលដៅ/ដៃគូ ដែលមិនត្រូវបានទាក់ទងដោយអន្តរាគមន៍ មុនៗ បានកាន់តែច្រើន ជាពិសេសក្រុមគោលដៅដែលមានហានិភ័យខ្ពស់ក្នុងការឆ្លងមេរោគអេដស៍
- ដើម្បីផ្តល់ជម្រើសបន្ថែមដល់ក្រុមគោលដៅ/ដៃគូ ក្នុងការទំនាក់ទំនងទៅរកសេវានានា តាមរយៈការប្រើប្រាស់បច្ចេកវិទ្យា
- ដើម្បីប្រមូលទិន្នន័យអង្កេតជាប្រចាំ ដែលនឹងរួមចំណែកធ្វើឱ្យប្រសើរឡើងនូវបទអន្តរាគមន៍បង្ការមេរោគអេដស៍តាមបែបនិម្មិត

វគ្គបណ្តុះបណ្តាល ត្រូវបានប្រារព្ធឡើង ក្រោមអធិតីភាព **លោក ម៉ែន ប៊ុនណាន** អនុប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្តកំពង់ចាម និង **លោកវេជ្ជ កាអឿនចិត្រា** តំណាងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ។




